Caritas CAMBODIA

*Ending poverty*
*Promoting Justice*
*Restore Dignity*

# របាយការណ៍សង្ខេប
# កម្មវិធីអភិវឌ្ឍន៍យុវជន

## ពិធីបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនជំនាន់ទី២៦ សិក្សាឆ្នាំ២០១៧ និងប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាម ជំនាន់ទី២៤-២៥ ឆ្នាំសិក្សា២០១៥-២០១៦

ភូមិតាក្តុល សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

# របាយការណ៍សង្ខេបស្តីពី
# កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់យុវជន

## ១. ប្រវត្តិសង្ខេបអង្គការការីតាសកម្ពុជា

### ក. សេចក្តីផ្តើម

អង្គការការីតាសកម្ពុជា គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងដោយព្រះសហគមន៍កាតូលិក កម្ពុជា ដើម្បីចូលរួមចំណែកលើសកម្មភាពមនុស្សធម៌ និងការអភិវឌ្ឍន៍សង្គម។ ជួយជនរងគ្រោះដោយសារសង្គ្រាម និងបានបំពេញមុខងារមនុស្សធម៌រហូតដល់ឆ្នាំ១៩៧៥ ដែលនៅពេលនោះអង្គការការីតាសកម្ពុជា ត្រូវបង្ខំអោយចាកចេញពីប្រទេសកម្ពុជា។ ការីតាសកម្ពុជា បានបង្កើតឡើងជាថ្មីនាឆ្នាំ១៩៩០ ក្រោមអនុស្សារណៈយោគយល់ជាមួយរដ្ឋាភិបាល លើសកម្មភាពមនុស្សធម៌ និងអភិវឌ្ឍន៍សុខមាលភាពប្រជាជនក្រីក្រ។ អង្គការការីតាស កម្ពុជាជាសមាជិក នៃអង្គការ ការីតាសអន្តរជាតិមានការិយាល័យនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី និងដែលមានបណ្តាញសមាជិកអង្គការ ការីតាសចំនួន១៦៧ប្រទេសនៅលើសកលលោក។

*ការីតាស(CARITAS) ជាពាក្យពេញនៃអក្សរឡាតាំងមានអត្ថន័យថា **មេត្តាករុណា ឬសេចក្តីស្រឡាញ់***

### ខ. ទស្សនៈវិស័យ

សង្គមមួយដែលមានយុត្តិធម៌ មានការគោរពសិទ្ធិគ្នាទៅវិញទៅមក ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ និងការអភិវឌ្ឍន៍នៃមនុស្សត្រូវបានលើកកម្ពស់។

### គ. បេសកកម្ម

ចូលរួមពង្រឹង និងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ជនក្រីក្រ និងជនងាយរងគ្រោះ

### ឃ. គោលការណ៍ដឹកនាំ និងគុណតម្លៃ

- លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្ស
- សមភាពយេនឌ័រ
- បរិស្ថាន និងនិរន្តរភាពកសិកម្ម
- ភាពម្ចាស់ការ និងសហការល្អ
- ជួយទំនុកបំរុងអ្នកជម្ងឺ
- លើកកម្ពស់ការអភិវឌ្ឍន៍រួមបញ្ចូលគ្នាមិនមានការរើសអើង
- កសាងភាពជាដៃគូ និងសហប្រតិបត្តិការ

### ង. កិច្ចសហប្រតិបត្តការ កម្មវិធីនានារបស់អង្គការ ការីតាស កម្ពុជា

បច្ចុប្បន្នអង្គការការីតាសកម្ពុជា បានរួមសហប្រតិបត្តិយ៉ាងជិតស្និទ្ធិជាមួយ ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សមាគម សហគមន៍ និងវិស័យឯកជន ដើម្បីធ្វើការងាររួមគ្នាក្នុងតំបន់គោលដៅចំនួន១២ខេត្ត និងរាជធានី ដែលរួមមាន៖ រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ចាម, ខេត្តក្រចេះ, ខេត្តរតនៈគិរី,

ខេត្តមណ្ឌលគិរី, ខេត្តស្ទឹងត្រែង, ខេត្តព្រះវិហារ, ខេត្តកំពង់ធំ, ខេត្តសៀមរាប, ខេត្តបាត់ដំបង, ខេត្តប៉ៃលិន និងខេត្តតាកែវ ដែលមានកម្មវិធីដូចខាងក្រោម៖

១-អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន
២-លើកកម្ពស់សន្តិសុខស្បៀង និងអភិវឌ្ឍន៍និរន្តរភាពមុខរបរចិញ្ចឹមជីវិត
៣-អភិវឌ្ឍន៍សុខភាពសហគមន៍
៤-ថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍
៥-ថែទាំសុខភាព និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទណ្ឌិតក្នុងពន្ធនាគារ
៦-ថែទាំ និងព្យាបាលសុខភាពផ្លូវចិត្តកុមារ និងមនុស្សពេញវ័យ
៧-ថែទាំ និងព្យាបាលសុខភាពភ្នែក និងបណ្តុះបណ្តាលគ្រូពេទ្យភ្នែក
៨-អភិវឌ្ឍន៍ចម្រុះនៅខេត្តមណ្ឌលគិរីសម្រាប់ជនជាតិដើម
៩-លើកកម្ពស់សិទ្ធិជាមូលដ្ឋាន យេនឌ័រ និងការប្រឆាំងការជួញដូរមនុស្ស
១០-អប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
១១-ឆ្លើយតប និងការត្រៀមបង្ការគ្រោះមហន្តរាយ

## ២. អំពីគម្រោងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

កម្មវិធីអភិវឌ្ឍន៍យុវជន ជាកម្មវិធីថ្នាក់ជាតិ ក្នុងចំណោមកម្មវិធីទាំងឡាយរបស់ អង្គការការីតាស កម្ពុជា។ កម្មវិធីនេះបានចាប់ផ្តើមក្នុងឆ្នាំ១៩៩២ ដែលបានធ្វើការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈដល់យុវជនក្រីក្រ ដែលមកពីគ្រប់បណ្តារាជធានី ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា អោយចូលរៀនដោយឥតបង់ថ្លៃ ប៉ុន្តែតម្រូវអោយចូលរួមបដិភាគទៅតាមសមត្ថភាព។

ចាប់តាំងពីឆ្នាំ១៩៩២ រហូតមកដល់បច្ចុប្បន្ន កម្មវិធីបាននេះផ្តល់ឱកាសដល់យុវជនសរុបចំនួន **២,៧៦៦នាក់** ក្នុងនោះស្រីចំនួន**៧៦៣នាក់** ទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗ ដើម្បីអោយពួកគាត់មានលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណូល និងបង្កើនទំនុកចិត្តអោយយុវជនស្គាល់ពីតួនាទីខ្លួនឯង ទាំងក្នុងគ្រួសារនិងក្នុងសង្គម ក៏ដូចជាធ្វើអោយពួកគាត់ ក្លាយជាពលរដ្ឋល្អក្នុងសង្គមផងដែរ។ ដែលយុវជនទាំងនោះសុទ្ធសឹងតែជាយុវជនដែលមកពីគ្រួសារក្រីក្រ ជាយុវជនកំព្រា ជាយុវជនពិការដែលពុំមានលទ្ធភាពរៀនបន្ត ជាយុវជនដែលគ្មានជំនាញពិតប្រាកដ ជាយុវជនចំណាកស្រុកនិងយុវជនងាយរងគ្រោះ។

ក្នុងចំណោមយុវជនដែលបានទទួលការបណ្តុះបណ្តាលជំនាញ មានយុវជនភាគច្រើនទទួលបានការងារធ្វើនៅតាម៖ បណ្តាស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងតាមក្រុមហ៊ុននានា ចំណែកយុវជនមួយចំនួនទៀតបានបើករោងជាងដោយខ្លួនឯងដូចជា៖ រោងជាងអ៊ុតសក់ រោងជាងកាត់សក់បុរស រោងជាងជួសជុលម៉ូតូ រោងជាងជួសជុលរថយន្តជាដើម។ ដោយឡែក, ក្នុងរយៈពេលពីរឆ្នាំចុងក្រោយគឺឆ្នាំ២០១៥ និងឆ្នាំ២០១៦ កម្មវិធីអភិវឌ្ឍន៍យុវជនបានផ្តល់ឱកាសដល់យុវជនចំនួន **១៤៣នាក់ ក្នុងនោះស្រី ៥១នាក់** ទទួលជំនាញបច្ចេកទេសដោយជោគជ័យ ។ បច្ចុប្បន្នក្នុងចំណោមយុវជន ,**១៤៣នាក់** មានយុវជនប្រម៉ាណ**១២០នាក់**ទទួលបានការងារធ្វើនៅតាម៖ បណ្តាស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងតាមក្រុមហ៊ុននានា យុវជនប្រហែល**១៣នាក់**ទៀតបានបើករោងជាងដោយខ្លួនឯងដូចជា៖ រោងជាងអ៊ុតសក់ រោងជាងកាត់សក់បុរស រោងជាងជួសជុលម៉ូតូ រោងជាងជួសជុលរថយន្តជាដើម។ល។ ជាទូទៅពួកគេអាចរកប្រាក់ចំណូលបានជាមធ្យម**ពី១២០ដុល្លារ ដល់២៥០ដុល្លារ** ក្នុងមួយខែ។ រីឯយុវជន**១០នាក់** កំពុងបន្តការសិក្សានៅមហាវិទ្យាល័យ។

### ក. គោលបំណងនៃកម្មវិធី

ដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពជីវិត ប្រែក្លាយយុវជនក្រីក្រនិងងាយរងគ្រោះ ជាប្រជាពលរដ្ឋល្អក្នុងសង្គម ធ្វើអោយពួកគាត់ក្លាយជាភ្នាក់ងារសង្គមសម្រាប់ទប់ស្កាត់៖ ការធ្វើចំណាកស្រុក ការកេងប្រវញ្ច័គ្រប់រូបភាព ការធ្លាក់ចូលជាពេស្យាចារដល់សហគមន៍របស់ពួកគាត់ តាមរយៈការផ្តល់អោយនូវជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍន៍ភាពជាសហគ្រិនភាព។

### ខ. ក្រុមគោលដៅរបស់គម្រោង

គម្រោងនេះនឹងផ្តល់សេវាកម្មជាពិសេសសម្រាប់យុវជន ដែលងាយរងគ្រោះមកពីគ្រប់ខេត្ត ក្រុង រាជធានី ទូទាំងប្រទេសកម្ពុជាដូចជា៖

- ជាយុវជនដែលមានអាយុចាប់ពី១៧ដល់២៥ឆ្នាំ
- យុវជនដែលក្រីក្រ និងងាយរងគ្រោះ មកពីតំបន់ដាច់ស្រយាលនិងទីក្រុង
- យុវជនកំព្រា និងពិការ
- យុវជនដែលបោះបង់ចោលការសិក្សា និងមិនមានជំនាញពិតប្រាកដ
- យុវជនចំណាកស្រុក មិនមានការងារធ្វើ
- យុវជនមកពីមណ្ឌលស្តារនិតិសម្បទានានា
- កម្មករកម្មការនីរោងចក្រកាត់ដេរ ។ល។

ក្នុងនោះដែរកម្មវិធីបានខិតខំប្រឹងប្រែងដើម្បីសម្រេចអោយបាននូវផែនការយុទ្ធសាស្ត្ររបស់ របស់ខ្លួនក្នុងការកសាងនូវក្តីសង្ឃឹមសម្រាប់យុវជនក្រីក្រ និងយុវជនងាយរងគ្រោះនៅក្នុងរូបភាពរួមបញ្ចូលតែមួយ ក្នុងការផ្តល់អំណាចដល់ពួកគេតាមរយៈ ការកសាងសមត្ថភាពធ្វើអោយពួកគាត់មានទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯង ដើម្បីអោយមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសហគមន៍ និងសង្គមរបស់ពួកគេ។

## ៣. សកម្មភាព និងលទ្ធផលសម្រេចបាន

### ក. បុគ្គលិកនិងគ្រូបណ្តុះបណ្តាលក្នុងកម្មវិធី

បច្ចុប្បន្ន, កម្មវិធីអភិវឌ្ឍន៍យុវជន មានបុគ្គលិកដែលកំពុងបំរើការងារសរុបចំនួន៨នាក់ ក្នុងនោះបុគ្គលិកស្រី១នាក់ និងគ្រូបណ្តុះបណ្តាលសរុប១៣នាក់ក្នុងនោះមាន៖ គ្រូបណ្តុះបណ្តាលអចិន្ត្រៃយ៍ក្នុងមណ្ឌល១នាក់ គ្រូក្រៅម៉ោង៥នាក់ និងគ្រូតាមរោងជាងសរុប៧នាក់។

### ខ. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

ក្នុងរយៈពេលពីរឆ្នាំចុងក្រោយគឺឆ្នាំ២០១៥ និងឆ្នាំ២០១៦នេះ កម្មវិធីអភិវឌ្ឍន៍យុវជន បានផ្តល់ឱកាសដល់យុវជនចំនួន **១៤៣នាក់ ក្នុងនោះស្រី ៥១នាក់** ទទួលជំនាញបច្ចេកទេសដោយជោគជ័យដូចខាងក្រោមនេះ៖

| ជំនាញ | ចំនួនសិស្សសរុប | ចំនួនសិស្សស្រី |
|---|---|---|
| *១ .ជំនាញក្នុងមណ្ឌល* | | |
| - រដ្ឋបាល និងមូលដ្ឋានគ្រឹះគណនេយ្យ | ៤០នាក់ | ៣១នាក់ |
| - កុំព្យូទ័រ | ៧នាក់ | ២នាក់ |
| - អភិវឌ្ឍន៍សហគមន៍ | ១៥នាក់ | ៧នាក់ |

| | | |
|---|---|---|
| - គំនូរ | ៦នាក់ | ០នាក់ |
| ***២. ជំនាញក្នុងរោងជាង*** | | |
| - គ្រប់គ្រងភោជនីយដ្ឋាន | ១៤នាក់ | ៦នាក់ |
| - កែសម្ផស្ស | ៥នាក់ | ៥នាក់ |
| - ជួសជុលម៉ាស៊ីនដេរ | ៤នាក់ | ០នាក់ |
| - កាត់សក់បុរស | ៣នាក់ | ០នាក់ |
| - ជួសជុលអគ្គីសនីនិងតបណ្ដាញ | ៥នាក់ | ០នាក់ |
| - ជួសជុលទូរសព្ទ័ដៃ | ៦នាក់ | ០នាក់ |
| - ជួសជុលអេឡិចត្រូនិច | ៣នាក់ | ០នាក់ |
| - ជួសជុលរថយន្ត | ១៧នាក់ | ០នាក់ |
| - ជួសជុលម៉ូតូ | ១១នាក់ | ០នាក់ |
| - ជួសជុលម៉ាស៊ីនត្រជាក់ | ៧នាក់ | ០នាក់ |
| **សរុប** | **១៤៣នាក់** | **៥១នាក់** |

ចំណោមយុវជន**១៤៣នាក់** មានយុវជនប្រម៉ាណ**១២០នាក់**ទទួលបានការងារធ្វើនៅតាមៈ បណ្ដាស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងតាមក្រុមហ៊ុននានា យុវជនប្រហែល**១៣នាក់**ទៀតបានបើករោងជាងដោយខ្លួនឯងដូចជាៈ រោងជាងអ៊ុតសក់ រោងជាងកាត់សក់បុរស រោងជាងជួសជុលម៉ូតូ រោងជាងជួស ជុលរថយន្តជាដើម។ល។ ជាទូទៅពួកគេអាចរកប្រាក់ចំណូលបានជាមធ្យម**ពី១២០ដុល្លារ ដល់២៥០ដុល្លារ** ក្នុងមួយខែ។ រីឯយុវជន**១០នាក់**ទៀតកំពុងបន្តរការសិក្សារនៅមហាវិទ្យាល័យ។

### គ. អន្តេវាសិកដ្ឋាន (ផ្ដល់អាហារ និងការស្នាក់នៅ)

ទន្ទឹមនឹងការផ្ដល់ដល់យុវជននូវជំនាញបច្ចេកទេស ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាពនិងគ្មានហានិភ័យ កម្មវិធីក៏បានផ្ដល់ដល់យុវជនផងដែរនូវ អន្តេវាសិកដ្ឋាន សំរាប់យុវជនក្រីក្រ យុវជនដែលមកពីតំបន់ដាច់ស្រយាល និងខេត្តឆ្ងាយៗសំរាប់ស្នាក់នៅ។ ដោយឡែក សុខភាពគឺជាផ្នែកមួយដែលគម្រោងកម្មវិធីបានយកចិត្តទុកដាក់ផងដែរ ព្រោះថាបើពួកគាត់មិនមានសុខភាពល្អ នោះនឹងធ្វើអោយមានការរំខានដល់ការសិក្សាជំនាញ ដូចនេះដើម្បីពួកគាត់មានសុខភាពមាំមួន អាហារបីពេលក្នុងមួយថ្ងៃ បានផ្ដល់សម្រាប់សិក្ខាកាមទាំងអស់ដែលសិក្សាជំនាញទាំងក្នុង និងក្រៅមណ្ឌល ដើម្បីអោយពួកគាត់អាចមាន លទ្ធភាពទទួលយកជំនាញនិងចំណេះដឹង ក្នុងការទទួលបានការងារសំរាប់អនាគតរបស់ពួកគាត់ជារៀងរាល់ឆ្នាំ។

### ឃ. ចងក្រងបណ្ដាញយុវជន

ដើម្បីយុវជនមានភាពស្និទ្ធស្នាល មានសាមគ្គីភាព ដាស់តឿនស្មារតី អោយយុវជនយល់ពីតួនាទីរបស់ខ្លួននៅក្នុងសង្គម ចេះជួយគ្នាជួយគ្នាទៅវិញទៅមក កម្មវិធីបានសម្របសម្រួលចងបណ្ដាញ និងបង្កើតក្លឹបយុវជនព្រមទាំងតម្រូវអោយយុវជនទាំងអស់ចូលរួមជាដាច់ខាតក្នុងសកម្មភាពសំខាន់ៗចំនួនបីគឺៈ (១).សកម្មភាពសង្គម

(២).សកម្មភាពសង្គ្រោះ (៣).កីឡា និងសកម្មភាពកំសាន្ត។ តាមរយៈសកម្មភាពទាំងអស់នេះយ៉ាងហោចណាស់បានបង្ករលក្ខណៈអោយយុវជនបានជួបប្រជុំ គ្នាជារៀងរាល់ខែ។

### ង. សកម្មភាពផ្សេងៗ

ក្រៅពីការសិក្សាជំនាញ ដើម្បីកសាងទំនុកចិត្តនិងភាពជឿជាក់ដល់សិក្ខាកាម យុវជនទាំងអស់បានផ្តល់ឪកាសអោយចូលរួមក្នុងសកម្មភាពនានា ដូចជា៖

- ការសិក្សាសាវជ្រាវផ្សេងៗ៖ កុំព្យូទ័រ រៀនអង់គ្លេស អានសៀវភៅ(បណ្ណាល័យសិក្សា) ការធ្វើទស្សនៈកិច្ចសិក្សា មើលឃ្លីបវិដេអូ អប់រំខ្លីៗជាដើម។ល។
- សិក្សាជំនាញបំណិនជីវិតដូចជា៖ ការជួយគ្នានៅក្នុងក្រុម ការរៀបចំផែនការអនាគត តួនាទីរបស់យុវជនទាំងក្នុងគ្រួសារនិងសង្គម ការគ្រប់គ្រងភាពតានតឹងតាមរយៈសិល្បៈ និងការលេងកីឡាផ្សេងៗជាដើម។ល។
- ការចូលរួមក្នុងការងារសង្គមដូចជា៖ វេទិកានិងសិក្ខាសាលាផ្សេងៗ ការធ្វើអនាម័យបរិដ្ឋាន ការធ្វើទស្សនៈកិច្ចសិក្សា ការចូលរួមក្នុងទិវាជាតិនិងអន្តរជាតិនានាដូចជា៖ ទិវាសិទ្ធនារី ទិវាអនាម័យបរិដ្ឋាន ទិវាដាំកូនឈើ ទិវាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ទិវាយុវជនអន្តរជាតិ ទិវាសិទ្ធមនុស្សអន្តរជាតិ។ល។
- ការសិក្សា និងអនុវត្តន៍ លើមូលដ្ឋានគ្រឹះនៃការដាំដំណាំបន្លែ និងការចិញ្ចឹមសត្វ។ សិក្ខាកាមទាំងអស់បានចូលរួមយ៉ាងសកម្មរួមជាមួយគ្នា ក្នុងការដាំដំណាំបន្លែ នៅក្នុងមណ្ឌល ដើម្បីផ្គត់ផ្គង់តម្រូវការផ្នែកម្ហូបអាហារផងដែរ។
- ដើម្បីកសាងនូវភាពជឿទុកចិត្ត និងបង្កើនភាពកក់ក្តៅដល់សិក្ខាកាម ក៏ដូចជាអាណាព្យាបាលមណ្ឌលបានបើកឱកាសឱ្យឪពុកម្តាយ សាច់ញាតិ មកសួរសុខទុក្ខ និងអនុញ្ញាតឱ្យសិក្ខាកាមទៅលេងផ្ទះក្នុងរយៈពេលពីរខែម្តង ដែលក្នុងម្តងមាន២ថ្ងៃ។
- ចំពោះការជំរុញលើកទឹកចិត្តសិក្ខាកាម ក៏ដូចជាបង្ហាញដល់អ្នកពាក់ព័ន្ធគ្រប់ស្រទាប់ ឱ្យបានស្គាល់កាន់តែច្រើន មណ្ឌលក៏បានទទួលភ្ញៀវទស្សនៈកិច្ចសិក្សាជាច្រើនដូចជា៖ អាជ្ញាធរថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ភ្ញៀវជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដៃគូរ និងប្រជាជនទូទៅផងដែរ។
- បើកឱកាសនិងផ្តល់ទីកន្លែងនៅក្នុងមណ្ឌល សម្រាប់ការប្រជុំបណ្តាញការងារ ដើម្បីពួកគាត់បានមើលឃើញនិងជឿទុកចិត្តក្នុងការបញ្ជូនយុវជនមកសិក្សាជំនាញ។

### *លទ្ធផលទាំងអស់ខាងលើ ទទួលបានពី៖*

- ការខិតខំប្រឹងប្រែងរបស់បុគ្គលិកគម្រោង និងការជួយជ្រោមជ្រែងពីមន្រ្តីថ្នាក់ជាតិ
- កិច្ចសហប្រតិបត្តការនិងគាំទ្រ យ៉ាងពេញទំហឹងពី រាជរដ្ឋាភិបាល តាំងពីថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ
- កិច្ចសហប្រតិបត្តការ និងគាំទ្រ ពីបណ្តាស្ថាប័នដៃគូ មិនមែនរដ្ឋាភិបាលនានា
- ការខិតខំ ប្រឹងប្រែង និងការប្តេជ្ញាចិត្ត របស់គ្រូជំនាញ និងសិក្ខាកាមទាំងអស់

## ៤. បញ្ហាប្រឈម

**ទោះជាយ៉ាងកម្មវិធីក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖**

- អត្ថប្រយោជន៍នៃការសិក្សាជំនាញបច្ចេកទេស នៅមិនទាន់បានបញ្ជ្រាបទូលំទូលាយដល់យុវជនដែលជាក្រុមគោលដៅ ជាពិសេសអាណាព្យាបាល ជាហេតុធ្វើអោយយុវជនមួយចំនួនមានអារម្មណ៍ថាការសិក្សាជំនាញ មិនទាន់សំខាន់ជាជាងរៀនបន្តទៅមហាវិទ្យាល័យ។
- ទំនោររបស់ប្រជាជននិងយុវជនមួយចំនួនធំគឺធ្វើចំណាកស្រុកទៅក្រៅប្រទេសជាជាងរៀនជំនាញ។
- យុវជនក្រីក្រខ្លាំង មិនមានឆន្ទៈនិងរៀនជំនាញរយៈពេលយូរជាជាងរកការងារធ្វើភ្លាមៗជាហេតុយុវជនមិនបានចាប់អារម្មណ៍និងជំនាញ។
- ទីផ្សារការងារមិនទាន់មានលក្ខណៈទូលាយ សម្រាប់រកការងារដែលមានកំរៃខ្ពស់ បន្ទាប់ពីរៀនចប់ ជាពិសេសកាងារដែលមានក្នុងមូលដ្ឋាន សហគមន៍ផ្ទាល់។

## ៥. ទិសដៅអនាគត

- ពង្រីកការសហប្រតិបត្តការល្អបន្ថែមទៀត លើសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងផ្សព្វផ្សាយអោយបានទូលំទូលាយដល់មូលដ្ឋានសហគមន៍ តំបន់ដាច់ស្រយាល សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើអោយគុណភាពនៃការអប់រំកាន់តែប្រសើរ និងមានតម្លៃ។
- បង្កើតអាជីវកម្មដោយមានការសហការពីយុវជនដែលបានបញ្ចប់ការសិក្សាជំនាញ ដើម្បីអោយពួកគាត់ក្លាយទៅជាសហគ្រិនវ័យក្មេង ជោគជ័យក្នុងសង្គម។
- ពង្រឹងគុណភាពបណ្តុះបណ្តាល និងជួយអោយយុវជនទទួលបានការងារ៩៥ភាគរយ នៃយុវជនបានបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យទាំងអស់។
- ភ្ជាប់ទំនាក់ទំនងជាមួយភ្នាក់ងារជាតិមុខរបរ និងការងារព្រមទាំងស្ថាប័នឯកជននានា ក្នុងការស្វែងរកការងារដល់យុវជន។

## ៦. សេចក្តីថ្លែងអំណរគុណ

ក្នុងនាមអង្គការការីតាសកម្ពុជា នឹងតំណាងអោយបុគ្គលិក និងសិក្ខាកាមទាំងអស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- **អង្គការ ការីតាសជប៉ុន**(Caritas Japan), Misereor **និង** Porticus Asia, ដែលបានគាំទ្រទាំងបច្ចេកទេស និងថវិកាសម្រាប់ ការអនុវត្តន៍គ្រោងរយៈពេលបីឆ្នាំ (២០១៤ ដល់ ២០១៧)។
- សូមថ្លែងអំណរគុណ ដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសព្រឹទ្ធសភាកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលតែងតែយកចិត្តទុកដាក់ សហប្រតិបត្តការ និងគាំទ្រយ៉ាងពេញទំហឹងនូវគ្រប់កិច្ចការទាំងអស់រហូតបានទទួលជោគជ័យគួរជាទីមោទនៈភាព។

យើងខ្ញុំសង្ឃឹមយ៉ាងមាំថា លោកអ្នកទាំងអស់នឹងនៅតែបន្តគាំទ្រគម្រោងនេះតទៅមុខទៀត ដើម្បីជួយដល់យុវជនក្រីក្រ និងងាយរងគ្រោះ ដែលត្រូវការ ការគាំទ្រពីពួកយើងទាំងផ្នែក ជំនាញ និងស្មារតី។

**សូមជូនពរ សុខភាពល្អ និងជ័យជំនះគ្រប់ភារៈកិច្ច!**

# សកម្មភាពរបស់យុវជនក្នុងអំឡុងពេលសិក្សាជំនាញ



យុវជនរៀនជុសជុលម៉ូតូ ក្នុងរោងជាងបច្ចេកទេស



យុវជនរៀនជំនាញកាត់សក់



សកម្មភាពយុវជនចុះទស្សនៈកិច្ចសិក្សាក្នុងអង្គការដៃគូ



សកម្មភាពអប់រំយុវជនក្នុងវគ្គតម្រង់ទិស



រូបថតយុវជនក្នុងថ្ងៃបើកវគ្គនិងទទួលវិញ្ញាបនបត្រ



យុវជនទទួលការបណ្តុះបណ្តាលពីការធ្វើម្ហូប



សិក្ខាសាលាស្តីពី យេនឌ័រ ការចំណាកស្រុក ការជួញដូរមនុស្ស



ការសិក្សាស្រាវជ្រាវ ក្នុងណ្ណាល័យ